# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់ អូហ្សូន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៤ / ២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញព្រះរាជក្រមលេខ នស / រកម /១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- យោងខ្លឹមសារអនុសញ្ញា ទីក្រុងវីយែន ស្តីពីកិច្ចការពារស្រទាប់ អូហ្សូន និងពិធីសារ ម៉ុងរ៉េអាល់ ស្តីពីសារធាតុ ដែលបំផ្លាញស្រទាប់ អូហ្សូន ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាចូលជាសមាជិក ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០១
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៥ ។

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .—**

អនុក្រឹត្យនេះមានគោលបំណង កំណត់ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់ អូហ្សូន (Ozone Layer) និងការគ្រប់គ្រងសកម្មភាពអាជីវកម្ម និងការប្រើប្រាស់សារធាតុនេះ ស្របតាមពិធីសារ ម៉ុងរ៉េអាល់ នៃអនុសញ្ញា ទីក្រុងវីយែន ។

**មាត្រា ២ .—**

អនុក្រឹត្យនេះអនុវត្តចំពោះរាល់ការនាំចូល ការនាំចេញ ការឆ្លងកាត់ ការផលិត ការស្តុកទុក ការលក់ដូរ ការដឹកជញ្ជូន និងការប្រើប្រាស់សារធាតុ ដែលបំផ្លាញស្រទាប់ អូហ្សូន (Ozone Layer) ទោះបីសារធាតុនោះមានលក្ខណៈទោល ឬសមាស នៅរក្សាភាពដើម ប្រើប្រាស់រួចហើយ ចំរាញ់ឡើងវិញ ឬក៏ធ្វើការកែប្រែគុណភាពក្នុងព្រះរាជាណាចក្រកម្ពុជាក៏ដោយ ។

**មាត្រា ៣ .—**

ពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ ៖

ក- **ស្រទាប់ អូហ្សូន** (Ozone Layer) សំដៅដល់ ឧស្ម័នអូហ្សូន($O_3$) ដែលប្រមូលផ្តុំស្ថិតនៅក្នុងបរិយាកាសតាមបែបធម្មជាតិ មានកម្ពស់ប្រហែល ៥០ គីឡូម៉ែត្រពីផែនដី ហើយមានបរិមាណប្រហែល ៩០ ភាគរយ នៃបរិមាណអូហ្សូនសរុបនៅលើផែនដី ។

ខ- **សារធាតុបំផ្លាញស្រទាប់ អូហ្សូន** (Ozone Layer) សំដៅដល់សារធាតុគីមី ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទាំងឡាយ ដែលមានឥទ្ធិពលប៉ះពាល់ចំពោះម៉ូលេគុលអូហ្សូន (Ozone) រួមមាន**សារធាតុ ក្លរ-ភ្លុយអរ៉ូកាបូន** [Chlorofluorocarbons (CFCs)] **សារធាតុ ហាយដ្រូក្លរ៉ូភ្លុយអរ៉ូកាបូន** [Hydrochlorofluorocarbons (HCFCs)] **សារធាតុ ម៉េទីលក្លរ៉ូហ្វម** (Methyl chloroform) **ហាឡូន** (Halon) **សារធាតុកាបូនតេត្រាក្លរ៉ាយ** (Carbon tetrachloride) **សារធាតុ ម៉េទីលប្រូម៉ាយ** (Methyl bromide) ឬសារធាតុ ទាំងឡាយដែលមានល្បាយសារធាតុ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ។

គ- **ផលិតផល** សំដៅដល់ផលិតផលទាំងឡាយ ដូចបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធទី ២នៃអនុក្រឹត្យនេះ ឬឧបសម្ព័ន្ធ D នៃពិធីសារ ម៉ុងរ៉េអាល់ ដែលមានផ្ទុក ឬដែលត្រូវគេបង្កើតឡើងដើម្បីប្រើប្រាស់សារធាតុ CFCs និងហាឡូន។

## ជំពូកទី ២
## ការនាំចូល ការនាំចេញ និងបែបបទសម្រាប់ការចុះបញ្ជី

**មាត្រា ៤ ._**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានបំណងនាំចូលសារធាតុបំផ្លាញស្រទាប់ អូហ្សូន ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ត្រូវចុះបញ្ជីនៅក្រសួងបរិស្ថាន ដើម្បីទទួលលិខិតអនុញ្ញាត ។ ចំពោះផលិតផល ដែលប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះតម្រូវឱ្យគ្រាន់តែចុះបញ្ជីនៅក្រសួងបរិស្ថានប៉ុណ្ណោះ ។

**មាត្រា ៥ ._**

ការស្នើសុំលិខិតអនុញ្ញាតនាំចូលសារធាតុបំផ្លាញស្រទាប់ អូហ្សូន លើកលែងតែសារធាតុ ហាយដ្រូក្លរ៉ូហ្លុយអរ៉ូកាបូន (HCFCs) ត្រូវធ្វើឡើងមិនឱ្យហួសពីហុកសិបថ្ងៃ (៦០ថ្ងៃ) បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន និងត្រូវធ្វើឱ្យបានមុនថ្ងៃទី ០១ ខែវិច្ឆិកា សម្រាប់ឆ្នាំបន្ទាប់ ។ ក្រសួងបរិស្ថានត្រូវធ្វើការសម្រេចលើពាក្យស្នើសុំ មិនឱ្យហួសពីថ្ងៃទី ០១ ខែធ្នូ ។

**មាត្រា ៦ ._**

ម្ចាស់សំណើត្រូវដាក់ពាក្យសុំនាំចូល សារធាតុ ហាយដ្រូក្លរ៉ូហ្លុយអរ៉ូកាបូន (HCFCs) ជូនក្រសួងបរិស្ថានពិនិត្យរយៈពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) មុនការនាំចូល ។

ក្រសួងបរិស្ថានត្រូវធ្វើការពិនិត្យ និងសម្រេច ចុះបញ្ជីមិនឱ្យលើសពីប្រាំពីរថ្ងៃ (០៧ថ្ងៃ) បន្ទាប់ពីបានទទួលការស្នើសុំ ។

**មាត្រា ៧ ._**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលបានចុះបញ្ជី និងបានទទួលលិខិតអនុញ្ញាតនាំចូល ត្រូវជូនដំណឹងទៅក្រសួងបរិស្ថាន ក្រោយពេលនាំចូលនីមួយៗ ។ ក្រោយពេលនាំចូល រាល់ប្រដាប់សម្រាប់ដាក់ដែលមានផ្ទុកសារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវតែមានបិទផ្លាកសញ្ញារបស់ក្រសួងបរិស្ថាន ។

**មាត្រា ៨ ._**

ផលិតផលដែលមានផ្ទុក ឬប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ដូចមានចែងក្នុង ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ ត្រូវហាមឃាត់ដាច់ខាតក្នុងការនាំចូល ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៦ ។

សារធាតុបំផ្លាញស្រទាប់ អូហ្សូន ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ត្រូវហាមឃាត់ដាច់ខាតក្នុងការនាំចូលចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១០ ។

**មាត្រា ៩ .-**

ករណីលើកលែងពិសេស នឹងត្រូវបានអនុវត្តក្នុងការអនុញ្ញាតនាំចូលសារធាតុបំផ្លាញស្រទាប់ អូហ្សូន និងផលិតផលដូចខាងក្រោម ៖

១- សារធាតុ ហាយដ្រូក្លរ៉ូភ្លុយអូរ៉ូកាបូន (HCFCs) អាចអនុញ្ញាតឱ្យនាំចូលរហូតដល់ឆ្នាំ២០៤០ ។

២- មេទីលប្រូម៉ាយ ដែលប្រើប្រាស់សម្រាប់បំបាត់កត្តាចង្រៃមុនការរៀបចំដឹកជញ្ជូន ។

៣- ផលិតផលឱសថ ដែលប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ក្នុងវិស័យសុខាភិបាល ។

៤- ហាឡូន ដែលប្រើប្រាស់ក្នុងការពន្លត់អគ្គិភ័យក្នុងវិស័យអាកាសចរណ៍ ។

៥- សារធាតុបំផ្លាញស្រទាប់ អូហ្សូន និងផលិតផលផ្សេងៗទៀត ដែលចេញប្រកាសដោយក្រសួងបរិស្ថានស្របតាមសេចក្តីសម្រេចអង្គប្រជុំភាគី នៃពិធីសារ ម៉ុងរ៉េអាល់ ។

**មាត្រា ១០ .-**

ការនាំចូលសារធាតុបំផ្លាញស្រទាប់ អូហ្សូន ឬផលិតផល ដូចមានបញ្ជាក់នៅក្នុងតារាង ឧបសម្ព័ន្ធទី១ និង ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ពីប្រទេសដែលមិនមែនជាសមាជិក នៃពិធីសារ ម៉ុងរ៉េអាល់ ត្រូវបានហាមឃាត់ ។ ក្រសួងបរិស្ថានត្រូវជូនដំណឹងអំពីប្រទេសដែលមិនមែនជាសមាជិកពិធីសារ ម៉ុងរ៉េអាល់ នៃអនុសញ្ញា ទីក្រុងវីយែន ។

**មាត្រា ១១ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានបំណងនាំចេញសារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវដាក់ពាក្យស្នើសុំទៅក្រសួងបរិស្ថានឱ្យបានមុនដប់ប្រាំថ្ងៃ (១៥ ថ្ងៃ) នៃការនាំចេញ ដើម្បីធ្វើការចុះបញ្ជី និងពិនិត្យសម្រេច ។

## ជំពូកទី ៣
## ការត្រួតពិនិត្យ ការធ្វើអាជីវកម្ម
## និងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន

**មាត្រា ១២ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលបាន និងកំពុង ឬមានបំណងដាក់លក់ លក់ ស្តុក ចែកចាយ ឬប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវធ្វើការកត់ត្រាឱ្យបានច្បាស់លាស់នូវបរិមាណ និងប្រភេទសារធាតុ ដែលលក់បានប្រចាំថ្ងៃ ដើម្បីងាយស្រួលដល់ការធ្វើអធិការកិច្ចរបស់ស្ថាប័នមានសមត្ថកិច្ច ។

រាល់ប្រដាប់សម្រាប់ដាក់ដែលមានផ្ទុកសារធាតុបំផ្លាញស្រទាប់ អូហ្សូន ទាំងអស់មុននឹងបញ្ចេញលក់ ឬចែកចាយត្រូវតែមានបិទផ្លាកសញ្ញាសម្គាល់ដែលចេញដោយក្រសួងបរិស្ថាន ។

**មាត្រា ១៣ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលបាន និងកំពុងប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន នៅក្នុងដំណើរការផលិតកម្មរបស់ខ្លួន ត្រូវមកធ្វើការចុះបញ្ជីនៅក្រសួងបរិស្ថាន ។ ចំពោះអាជីវកម្មដែលមានស្រាប់ត្រូវមកចុះបញ្ជីយ៉ាងយូរកៅសិបថ្ងៃ (៩០ថ្ងៃ) បន្ទាប់ពីការចូលជាធរមាននៃអនុក្រឹត្យនេះ ។

**មាត្រា ១៤ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានបំណងធ្វើការពង្រីក ឬការបង្កើតថ្មី នូវប្រព័ន្ធដែលប្រើប្រាស់សារធាតុ CFCs សម្រាប់ផលិតកម្មក្នុងរោងចក្រ-សហគ្រាសរបស់ខ្លួន ត្រូវហាមឃាត់ជាដាច់ខាត ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ។

**មាត្រា ១៥ .-**

រាល់ការផ្ទេរប្រដាប់សម្រាប់ដាក់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ពីមួយទៅមួយ ត្រូវតែសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ។

## ជំពូកទី ៤
## ការសំអាតឡើងវិញ ការកែច្នៃ និងការបំផ្លាញចោលសារធាតុបំផ្លាញស្រទាប់ អូហ្សូន

**មាត្រា ១៦ .-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ : សំអាត សំដៅដល់ការរចនាឡើងវិញ នូវសារធាតុអ្វីមួយ ដែលមានន័យជាភាសាអង់គ្លេសថា Recycle ។

**មាត្រា ១៧ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គលណាក៏ដោយ មិនអាចធ្វើការសំអាតឡើងវិញ នូវសារធាតុបំផ្លាញស្រទាប់ អូហ្សូន ដែលបានប្រើប្រាស់រួចហើយ លើកលែងតែមានការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ១៨ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលមានបំណងធ្វើការបំផ្លាញចោល ឬកែច្នៃ នូវសារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវមានឧបករណ៍បច្ចេកទេសដែលទទួលការអនុញ្ញាតពីក្រសួងបរិស្ថាន ដោយរួមសហការជាមួយ ក្រសួង[illegible] ។

## ជំពូកទី ៥
## ការត្រួតពិនិត្យឧបករណ៍ធ្វើឱ្យត្រជាក់

**មាត្រា ១៩ ..**

សេវាកម្មជួសជុលម៉ាស៊ីនត្រជាក់ ទូទឹកកក ឬ ឧបករណ៍ធ្វើឱ្យត្រជាក់គ្រប់ប្រភេទ មិនអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរប្រព័ន្ធដែលកំពុងប្រើប្រាស់សារធាតុជំនួស ទៅប្រើប្រាស់សារធាតុ CFCs វិញ ជាដាច់ខាត ។

**មាត្រា ២០ ..**

ការផ្តល់ប័ណ្ណសម្គាល់យានយន្តគ្រប់ប្រភេទ ដែលមានប្រព័ន្ធម៉ាស៊ីនត្រជាក់ប្រើប្រាស់សារធាតុ CFCs ត្រូវហាមឃាត់ដាច់ខាត ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៦ ។

**មាត្រា ២១ ..**

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន ក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងអនុវត្តតាមមាត្រា២០ នៃអនុក្រឹត្យនេះ ។ បែបបទក្នុងការគ្រប់គ្រងត្រួតពិនិត្យ និងអនុវត្តបទប្បញ្ញត្តិ ដូចបានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ នឹងកំណត់ដោយប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ៦
## ការលប់បំបាត់សារធាតុបំផ្លាញស្រទាប់ អូហ្សូន

**មាត្រា ២២ ..**

ការនាំចូលសារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវអនុវត្តតាមកម្មវិធីលប់បំបាត់សារធាតុបំផ្លាញស្រទាប់ អូហ្សូន នៃពិធីសារ ម៉ុងរ៉េអាល់ ដោយយោងតាមកម្រិត នៃការប្រើប្រាស់នៅក្នុង កម្មវិធីជាតិសម្រាប់ការលប់បំបាត់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ដូចខាងក្រោម ៖

- ថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩ : -កម្រិតការប្រើប្រាស់សារធាតុ CFCs នៅក្នុង ឧបសម្ព័ន្ធទី១ ឱ្យនៅត្រឹមកម្រិតមធ្យម នៃចន្លោះឆ្នាំ ១៩៩៥-១៩៩៧ ។
- ថ្ងៃទី០១ ខែមករា ឆ្នាំ២០០២ : -កម្រិតការប្រើប្រាស់សារធាតុ ហាឡូន ឱ្យនៅត្រឹមកម្រិតមធ្យម នៃចន្លោះឆ្នាំ ១៩៩៥-១៩៩៧ ។
  -កម្រិតការប្រើប្រាស់សារធាតុ មេទីលប្រូម៉ាយ ឱ្យនៅត្រឹមកម្រិតមធ្យមនៃចន្លោះឆ្នាំ១៩៩៥-១៩៩៨ ។
- ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៣ : -សារធាតុ CFCs នៅក្នុងឧបសម្ព័ន្ធទី២ ក្រុម១ ត្រូវកាត់បន្ថយ

នៅត្រឹម ២០ ភាគរយ នៃការប្រើប្រាស់ជាមធ្យម ក្នុងចន្លោះឆ្នាំ ១៩៩៨-២០០០ ។

-កម្រិតការប្រើប្រាស់សារធាតុ ម៉េទីលប្រូម៉ាយ ឱ្យនៅត្រឹមកម្រិតមធ្យមនៃចន្លោះឆ្នាំ១៩៩៥-២០០០។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ : -សារធាតុ CFCs នៅក្នុងឧបសម្ព័ន្ធទី១ ត្រូវកាត់បន្ថយនៅត្រឹម ៥០ ភាគរយ នៃការប្រើប្រាស់ជាមធ្យមក្នុងចន្លោះឆ្នាំ ១៩៩៥-១៩៩៧ ។

-សារធាតុ ហាឡូន ត្រូវកាត់បន្ថយនៅត្រឹម ៥០ ភាគរយ ឱ្យនៅត្រឹមកម្រិតមធ្យម នៃចន្លោះឆ្នាំ ១៩៩៥-១៩៩៧ ។

-សារធាតុ កាបូនតេត្រាក្លរ៉ាយ ត្រូវកាត់បន្ថយនៅត្រឹម ៨៥ ភាគរយ នៅត្រឹមកម្រិតមធ្យម នៃចន្លោះឆ្នាំ ១៩៩៨-២០០០ ។

-សារធាតុ ម៉េទីលក្លរ៉ូហ្វម ត្រូវកាត់បន្ថយនៅត្រឹម ៣០ ភាគរយ នៃការប្រើប្រាស់ជាមធ្យមក្នុងចន្លោះ ឆ្នាំ ១៩៩៨-២០០០ ។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ : - សារធាតុ CFCs នៅក្នុងឧបសម្ព័ន្ធទី១ ត្រូវកាត់បន្ថយនៅត្រឹម ៨៥ ភាគរយ នៃការប្រើប្រាស់ជាមធ្យម ក្នុងចន្លោះឆ្នាំ ១៩៩៥-១៩៩៧ ។

- សារធាតុ CFCs នៅក្នុងឧបសម្ព័ន្ធទី២ ត្រូវកាត់បន្ថយនៅត្រឹម ៨៥ ភាគរយ នៃការប្រើប្រាស់ជាមធ្យម ក្នុងចន្លោះឆ្នាំ ១៩៩៨-២០០០ ។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ : - សារធាតុ CFCs ហាឡូន និងកាបូនតេត្រាក្លរ៉ាយ លុបបំបាត់ចោល។

- សារធាតុ ម៉េទីលក្លរ៉ូហ្វម កាត់បន្ថយនៅត្រឹម ៧០ ភាគរយ នៃការប្រើប្រាស់ជាមធ្យម ក្នុងចន្លោះឆ្នាំ ១៩៩៨-២០០០ ។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ : -សារធាតុ ម៉េទីលក្លរ៉ូហ្វម និង ម៉េទីលប្រូម៉ាយ ត្រូវលុបបំបាត់ចោល ។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ : -កម្រិតការប្រើប្រាស់សារធាតុ HCFCs តាមតួលេខជាមូលដ្ឋាននៃការប្រើប្រាស់ជាមធ្យមនៅក្នុង ឆ្នាំ ២០១៥។

- ថ្ងៃទី០១ ខែមករា ឆ្នាំ២០៤០ : - សារធាតុ HCFCs ត្រូវលុបបំបាត់ចោល ។

## ជំពូកទី ៧
## ការតាមដានត្រួតពិនិត្យ និងការគ្រប់គ្រង
## សារធាតុបំផ្លាញស្រទាប់ អូហ្សូន

**មាត្រា ២៣ ._**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលបាន និងកំពុងធ្វើអាជីវកម្ម ឬមានបំណងនឹងធ្វើអាជីវកម្មសារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវបញ្ជូនកំណត់ត្រា និងរបាយការណ៍ ដែលទាក់ទងនឹងការធ្វើអាជីវកម្មប្រចាំឆ្នាំមក ក្រសួងបរិស្ថាន ។

**មាត្រា ២៤ ._**

អង្គភាពទទួលបន្ទុកគ្រប់គ្រងអូហ្សូនជាតិស្ថិតក្រោមក្រសួងបរិស្ថាន មានភារកិច្ចអនុវត្តដូចខាងក្រោមនេះ ៖

- បំពេញតួនាទីជាមជ្ឈមណ្ឌលសម្របសម្រួលរវាងក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីទទួលរបាយការណ៍ ស្តីពីការត្រួតពិនិត្យ ការនាំចូល នាំចេញ ការផលិត និងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន
- សម្របសម្រួលការងារជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំផែនការលម្អិត កម្មវិធី និងបទដ្ឋានក្នុងការលប់បំបាត់ការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន
- ធ្វើរបាយការណ៍ ស្តីពីការគ្រប់គ្រង ការត្រួតពិនិត្យ និងការវាយតម្លៃចំពោះការនាំចេញ នាំចូល ការផលិត និងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ជូនរាជរដ្ឋាភិបាលកម្ពុជា
- តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិ សម្រាប់លប់បំបាត់សារធាតុបំផ្លាញស្រទាប់ អូហ្សូន និងធ្វើគម្រោងទាក់ទងនឹងការលប់បំបាត់ចោល សារធាតុបំផ្លាញស្រទាប់ អូហ្សូន
- សម្របសម្រួលជាមួយអង្គការអន្តរជាតិ អង្គការតំបន់ និងផ្នែកអូហ្សូនជាតិ នៃបណ្តាប្រទេសដទៃទៀត ដើម្បីផ្លាស់ប្តូរព័ត៌មាន ការផ្តល់យោបល់អំពីគោលនយោបាយ និងជំនួយការផ្នែកបច្ចេកទេសក្នុងកិច្ចការពារស្រទាប់ អូហ្សូន
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីបច្ចេកទេស អំពីបច្ចេកទេសត្រួតពិនិត្យសារធាតុបំផ្លាញស្រទាប់ អូហ្សូន
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពចំពោះមន្ត្រីបច្ចេកទេស និងផ្នែកឯកជន ពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុជំនួស និងការប្រើប្រាស់ឡើងវិញនៃសារធាតុបំផ្លាញស្រទាប់ អូហ្សូន
- អប់រំ និងលើកកម្ពស់ការយល់ដឹង អំពីសារធាតុបំផ្លាញស្រទាប់ អូហ្សូន ដល់អ្នកពាក់ព័ន្ធទាំងអស់ ដោយធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុងការចេញបទបញ្ជាដើម្បីបញ្ឈប់ ឬផ្អាកសកម្មភាពទាំងឡាយដែលទាក់ទងនឹងសារធាតុបំផ្លាញស្រទាប់ អូហ្សូន នៅពេលណាដែលពិនិត្យឃើញថា សកម្មភាពទាំងនោះបណ្តាលឱ្យមានការប៉ះពាល់ដល់ស្រទាប់ អូហ្សូន

- ធ្វើសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ ក្នុងតំបន់ដើម្បីកិច្ចការពារស្រទាប់ អូហ្សូន

**មាត្រា ២៥ ...**

ផែនការសកម្មភាព ស្តីពីការតាមដាន និងការត្រួតពិនិត្យ សារធាតុបំផ្លាញស្រទាប់ អូហ្សូន នៅក្នុងអាជីវកម្មជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ អ្នកផលិត និងអ្នកប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ត្រូវចូលរួមសហការជាមួយមន្ត្រីត្រួតពិនិត្យតាមការស្នើសុំ ។

ក្នុងករណី ចាំបាច់ការត្រួតពិនិត្យអាចត្រូវធ្វើជាបន្ទាន់ ។

**មាត្រា ២៦ ...**

គំរូពាក្យស្នើសុំចុះបញ្ជី លិខិតអនុញ្ញាត គំរូកំណត់ត្រា ដូចមានចែងនៅក្នុងមាត្រា ៤ ៥ ១១ ១២ និងមាត្រា ១៣ ចេញដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ២៧ ...**

ក្រសួងបរិស្ថានត្រូវចេញសេចក្តីព្រមានជាលាយលក្ខណ៍អក្សរ ចំពោះជនណាដែលល្មើសនឹងមាត្រា ១២ ១៣ ១៥ ១៧ ១៨ ១៩ និងមាត្រា ២៣ នៃអនុក្រឹត្យនេះ។

ក្នុងករណីចចេសរឹងរូស ឬមិនព្រមអនុវត្តតាម ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិ នៃ មាត្រា ២១ ជំពូកទី ៩ នៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**មាត្រា ២៨ ...**

ជនណាដែលល្មើសនឹងមាត្រា៨ ១០ និងមាត្រា១៤ នៃអនុក្រឹត្យនេះ ឬមិនអនុញ្ញាត ឬរារាំងមន្ត្រីអធិការកិច្ចរបស់ក្រសួងបរិស្ថានធ្វើការត្រួតពិនិត្យ ឬបំពេញបេសកកម្មរបស់ខ្លួនក្នុងការអនុវត្តអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃមាត្រា២១ ជំពូកទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ២៩ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣០
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យ
## លេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៥
## ស្តីពី ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់ អូហ្សូន

### តារាងសារធាតុបំផ្លាញស្រទាប់ អូហ្សូន

| ឈ្មោះ/ក្រុម | ឈ្មោះគីមី | រូបមន្ត | និមិត្តសញ្ញា | លេខកូដ | កំរិតឥទ្ធិពលបំផ្លាញ អូហ្សូន |
|---|---|---|---|---|---|
| | **Halogenated derivatives of hydrocarbons** | | | | |
| **ផ្នែក ក ក្រុមទី ១ (CFC)** | **Halogenated derivatives of acyclic hydrocarbons containing two or more different halogens** | | | | |
| CFC-11 | Trichlorofluoromethane | $CFCL_3$ | R-11 | 2903.41.00 | 1.0 |
| CFC-12 | Dichlorodifluoromethane | $CF_2CL_3$ | R-12 | 2903.42.00 | 1.0 |
| CFC-113 | Trichlorotrifluoroethane | $C_2F_3CL_3$ | R-113 | 2903.43.00 | 0.8 |
| CFC-114 | Dichlorotetrafluoroethanes | $C_2F_4CL_2$ | R-114 | 2903.44.00 | 1.0 |
| CFC-115 | Chloropentafluoroethane | $CCLF_2CF_3$ | R-115 | 2903.44.00 | 0.6 |
| **ផ្នែក ក ក្រុមទី ២ (Halon)** | **Halogenated derivatives of acyclic hydrocarbons containing two or more different halogens** | | | | |
| Halon-1211 | Bromochlorodifluoromethane | $CF_2BrCL$ | R-12B1 | 2903.46.00 | 3.0 |
| Halon-1301 | Bromotrifluoromethane | $CF_3Br$ | R-13B1 | 2903.46.00 | 10.0 |
| Halon-2402 | Dibromotetrafluoroethane | $C_2F_4Br_2$ | R-114B2 | 2903.46.00 | 6.0 |
| **ផ្នែក ខ ក្រុមទី ១ (CFC)** | **other derivates perhalogenated only with fluorine and chlorine** | | | | |
| CFC-13 | Chlorotrifluomathane | $CF_3CL$ | R-13 | 2903.45.10 | 1.0 |
| CFC-111 | Pentachlorofluoroethane | $C_2FCL_5$ | R-111 | 2903.45.21 | 1.0 |
| CFC-112 | Tetrachlorodifluoroethane | $C_2F_2CL_4$ | R-112 | 2903.45.22 | 1.0 |
| CFC-211 | Heptachlorofluoropropane | $C_3FCL_7$ | | 2903.45.31 | 1.0 |
| CFC-212 | Hexachlorodifluoropropane | $C_3F_2CL_6$ | | 2903.45.32 | 1.0 |
| CFC-213 | Pentachlrorotrifluoropropane | $C_3F_3CL_5$ | | 2903.45.33 | 1.0 |
| CFC-214 | Tetrachlorotetrafluoropropane | $C_3F_4CL_4$ | | 2903.45.34 | 1.0 |
| CFC-215 | Trichloropentafluoropropane | $C_3F_5CL_3$ | | 2903.45.35 | 1.0 |
| CFC-216 | Dichlorohexafluoropropane | $C_3F_6CL_2$ | | 2903.45.36 | 1.0 |
| CFC-217 | Chloroheptafluoropropane | $C_3F_7CL$ | | 2903.45.37 | 1.0 |
| **ផ្នែក ខ ក្រុមទី ២** | **Saturated chlorinated derivatives of acyclic hydrocarbons** | | | | |
| | Tetrachlormethane of carbon tetrachloride | $CCL_4$ | | 2903.14.00 | 1.1 |
| **ផ្នែក ខ ក្រុមទី ៣** | **Other** | | | | |
| | 1,1,1-trichloroethane or methyl chloroform | $C_2H_3CL_3$ (1) | R-140a | 2903.19.10 | 0.1 |
| **ផ្នែក គ ក្រុមទី ១ (HCFC)** | | | | | |
| HCFC-21 | | $CHFCL_2$ | R-21 | 2903.49.10 | 0.04 |
| HCFC-22 | | $CHF_2CL$ | R-22 | 2903.49.10 | 0.055 |
| HCFC-31 | | $CH_2FCL$ | R-31 | 2903.49.10 | 0.02 |

| | | | | | |
|---|---|---|---|---|---|
| HCFC-121 | Tetrachlorofluoroethanes | $C_2HFCL_4$ | | 2903.49.10 | 0.01-0.04 |
| HCFC-122 | Trichlorodifluoroethanes | $C_2HF_2CL_3$ | | 2903.49.10 | 0.02-0.08 |
| HCFC-123 | Dichlorotrifluoroethanes | $C_2HF_3CL_2$ | R-123 | 2903.49.10 | 0.02-0.06 |
| HCFC-123 | 2,2-dichloro-1,1,1-trifluoroethanes | $CHCL_2CF_3$ | | 2903.49.10 | 0.02 |
| HCFC-124 | Chlorotetrachloroethanes | $C_2HF_4CL$ | | 2903.49.10 | 0.02-0.04 |
| HCFC-124 | 2-chloro-1,1,1,2-tetrafluoroethane | $CHFCLCF_3$ | R-124 | 2903.49.10 | 0.022 |
| HCFC-131 | Trichlorofluoroethanes | $C_2H_2FCL_3$ | | 2903.49.10 | 0.007-0.05 |
| HCFC-132 | Dichlorodifluoroethanes | $C_2H_2F_2CL_2$ | | 2903.49.10 | 0.008-0.05 |
| HCFC-133 | Chlorotrifluoroethanes | $C_2H_2F_3CL$ | | 2903.49.10 | 0.02-0.06 |
| HCFC-141 | Dichlorofluoroethanes | $C_2H_3FCL_2$ | | 2903.49.10 | 0.005-0.07 |
| HCFC-141b | 1,1-dichloro-1-fluoroethane | $CH_3CFCL_2$ | R-141b | 2903.49.10 | 0.011 |
| HCFC-142 | Chlorodifluoroethanes | $C_2H_3F_2CL$ | | 2903.49.10 | 0.008-0.07 |
| HCFC-142b | 1-chloro-1,1-difluoroethane | $CH_3CF_2CL$ | R-142b | 2903.49.10 | 0.065 |
| HCFC-151 | Chlorofluoroethanes | $C_2H_4FCL$ | | 2903.49.10 | 0.003-0.005 |
| HCFC-221 | Hexachlorofluoropropanes | $C_3HFCL_6$ | | 2903.49.10 | 0.015-0.07 |
| HCFC-222 | Pentachlorodifluoropropanes | $C_3HF_2CL_5$ | | 2903.49.10 | 0.01-0.09 |
| HCFC-223 | Tetrachlorotrifluoropropanes | $C_3HF_3CL_4$ | | 2903.49.10 | 0.01-0.08 |
| HCFC-224 | Trichlorotetrafluoropropanes | $C_3HF_4CL_3$ | | 2903.49.10 | 0.01-0.09 |
| HCFC-225 | Dichloropentafluoropropanes | $C_3HF_5CL_2$ | | 2903.49.10 | 0.02-0.07 |
| HCFC-225ca | 1-1-dichloro-2,2,3,3,3-pentafluoropropane | $CF_3CF_2CHCL_2$ | R-225ca | 2903.49.10 | 0.025 |
| HCFC-225cb | 1,3-dichloro-1,2,2,3,3-pentafluoropropane | $CF_2CLCF_2CHCLF$ | R-225cb | 2903.49.10 | 0.033 |
| HCFC-226 | Chlorohexafluoropropanes | $C_3HF_6CL$ | | 2903.49.10 | 0.02-0.10 |
| HCFC-231 | Pentachlorofluoropropanes | $C_3H_2FCL_5$ | | 2903.49.10 | 0.05-0.09 |
| HCFC-232 | Tetrachlorodifluoropropanes | $C_3H_2F_2CL_4$ | | 2903.49.10 | 0.008-0.10 |
| HCFC-233 | Trichlorotrifluoropropanes | $C_3H_2F_3CL_3$ | | 2903.49.10 | 0.007-0.23 |
| HCFC-234 | Dichlorotetrafluoropropanes | $C_3H_2F_4CL_2$ | | 2903.49.10 | 0.01-0.28 |
| HCFC-235 | Chloropentafluoropropanes | $C_3H_2F_5CL$ | | 2903.49.10 | 0.03-0.52 |
| HCFC-241 | Tetrachlorofluoropropanes | $C_3H_3FCL_4$ | | 2903.49.10 | 0.004-0.09 |
| HCFC-242 | Trichlorodifluoropropanes | $C_3H_3F_2CL_3$ | | 2903.49.10 | 0.005-0.13 |
| HCFC-243 | Dichlorotrifluoropropanes | $C_3H_3F_3CL_2$ | | 2903.49.10 | 0.007-0.12 |
| HCFC-244 | Chlorotetrafluoropropanes | $C_3H_3F_4CL$ | | 2903.49.10 | 0.009-0.14 |
| HCFC-251 | Trichlorotetrafluoropropanes | $C_3H_4FCL_3$ | | 2903.49.10 | 0.001-0.01 |
| HCFC-252 | Dichlorodifluoropropanes | $C_3H_4F_2CL_2$ | | 2903.49.10 | 0.005-0.04 |
| HCFC-253 | Chlorotrifluoropropanes | $C_3H_4F_3CL$ | | 2903.49.10 | 0.003-0.03 |
| HCFC-261 | Dichlorofluoropropanes | $C_3H_5FCL_2$ | | 2903.49.10 | 0.002-0.02 |
| HCFC-262 | Chlorodifluoropropanes | $C_3H_5F_2CL$ | | 2903.49.10 | 0.002-0.02 |
| HCFC-271 | Chlorofluoropropanes | $C_3H_6FCL$ | | 2903.49.10 | 0.001-0.03 |
| **ផ្នែក គ**<br>**ក្រុមទី ២ (HBFC)** | **Derivates of methane, ethane or propane halogenated only with fluorine and bromine** | | | | |
| | | $CHFBr_2$ | | 2903.49.20 | 1.0 |
| HBFC-22B1 | Bromodifluoromethane | $CHF_2Br$ | R-22B1 | 2903.49.20 | 0.74 |
| | | $CH_2FBr$ | | 2903.49.20 | 0.73 |
| | | $C_2HFBr_4$ | | 2903.49.20 | 0.3-0.8 |
| | | $C_2HF_2Br_3$ | | 2903.49.20 | 0.5-1.8 |
| | | $C_2HF_3Br_2$ | | 2903.49.20 | 0.4-1.6 |
| | | $C_2HF_4Br$ | | 2903.49.20 | 0.7-1.2 |
| | | $C_2H_2FBr_3$ | | 2903.49.20 | 0.1-1.1 |
| | | $C_2H_2F_2Br_2$ | | 2903.49.20 | 0.2-1.5 |
| | | $C_2H_2F_3Br$ | | 2903.49.20 | 0.7-1.6 |
| | | $C_2H_3FBr_2$ | | 2903.49.20 | 0.1-1.7 |
| | | $C_2H_3F_2Br$ | | 2903.49.20 | 0.2-1.1 |
| | | $C_2H_4Br$ | | 2903.49.20 | 0.07-0.1 |
| | | $C_3HFBr_6$ | | 2903.49.20 | 0.3-1.5 |
| | | $C_3HF_2Br_5$ | | 2903.49.20 | 0.2-1.9 |
| | | $C_3HF_3Br_4$ | | 2903.49.20 | 0.3-1.8 |
| | | $C_3HF_4Br_3$ | | 2903.49.20 | 0.5-2.2 |
| | | $C_3HF_5Br_2$ | | 2903.49.20 | 0.9-2.0 |
| | | $C_3HF_6Br$ | | 2903.49.20 | 0.7-3.3 |
| | | $C_3H_2FBr_5$ | | 2903.49.20 | 0.1-1.9 |
| | | $C_3H_2F_2Br$ | | 2903.49.20 | 0.2-5.6 |
| | | $C_3H_2F_4Br_2$ | | 2903.49.20 | 0.3-7.5 |

| | | | | | |
|---|---|---|---|---|---|
| | | $C_3H_2F_5Br$ | | 2903.49.20 | 0.9-1.4 |
| | | $C_3H_3FBr_4$ | | 2903.49.20 | 0.08-1.9 |
| | | $C_3H_3F_2Br_3$ | | 2903.49.20 | 0.1-3.1 |
| | | $C_3H_3F_3Br_2$ | | 2903.49.20 | 0.1-2.5 |
| | | $C_3H_3F_4Br$ | | 2903.49.20 | 0.3-4.4 |
| | | $C_3H_4FBr_3$ | | 2903.49.20 | 0.03-0.3 |
| | | $C_3H_4F_2Br_2$ | | 2903.49.20 | 0.1-1.0 |
| | | $C_3H_4F_3Br$ | | 2903.49.20 | 0.07-0.8 |
| | | $C_3H_5FBr_2$ | | 2903.49.20 | 0.04-0.4 |
| | | $C_3H_5F_2Br$ | | 2903.49.20 | 0.07-0.8 |
| | | $C_3H_6FBr$ | | 2903.49.20 | 0.02-0.7 |
| **ផ្នែក គ ក្រុមទី ៣** | **Derivates of methane, ethane or propane, halogenated only with bromine and chlorine** | | | | |
| | Bromochloromethane | $CH_2BrCL$ | | 2903.49.90 | 0.12 |
| **ផ្នែក ខ ក្រុមទី ១** | **Fluorinated, brominated of iodinated derivates of acyclic hydrocarbons** | | | | |
| MB | Methyl bromide | $CH_3Br$ | | 2903.30.20 | 0.6 |

**កំណត់សម្គាល់**

1. រូបមន្តនេះមិនសំដៅទៅលើ 1,1,2-trichloroethane ទេ ។

ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យ

លេខ ៤៧៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៥

ស្តីពី ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់ អូហ្សូន

## បញ្ជីឈ្មោះផលិតផលប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន[១]
## ដែលត្រូវចុះបញ្ជីនៅក្រសួងបរិស្ថាន

| ក្រុម | ប្រភេទ | លេខសម្គាល់ក្នុងតារាងពន្ធគយកម្ពុជា[៦] |
|---|---|---|
| ១ | **ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនសម្រាប់ផ្លាស់ប្តូរសីតុណ្ហភាព និងសំណើម ទូទឹកកក ទូបង្កក និងកុំប្រេសស័រដែលធ្វើឱ្យត្រជាក់[២]** | |
| | **ក. កុំប្រេសស័រដែលធ្វើឱ្យត្រជាក់:** | |
| | - កុំប្រេស័រ នៃប្រភេទប្រើក្នុងឧបករណ៍ធ្វើឱ្យត្រជាក់ : | |
| | - - មានកម្លាំងលើសពី ២១ គីឡូវ៉ាត់/ម៉ោងឬ ច្រើនជាង ដែលមានទំហំប្រើប្រាស់ប្រេង ២២០ សម $^{៣}$ ឬច្រើនជាងនេះ : | |
| | - - - សម្រាប់ម៉ាស៊ីនត្រជាក់ ឧបករណ៍ត្រជាក់ | 8414.30.11 |
| | - - - ផ្សេងទៀត | 8414.30.19 |
| | - - ផ្សេងទៀត : | |
| | - - - សម្រាប់ម៉ាស៊ីនត្រជាក់ ឧបករណ៍ត្រជាក់ | 8414.30.91 |
| | - - - ផ្សេងទៀត | 8414.30.99 |
| | - - កុំប្រេស័រក្រៅពីទីតាំងរងលេខ៨៤១៤.៣០ និង ៨៤១៤.៤០ | |
| | - - - កុំប្រេស័រសម្រាប់ម៉ាស៊ីនត្រជាក់រថយន្ត | 8414.80.42 |
| | - - - ឧបករណ៍បិទជាប់សម្រាប់ប្លុកម៉ាស៊ីនត្រជាក់ | 8414.80.43 |
| | - - - កុំប្រេស័រផ្សេងទៀត | 8414.80.49 |
| | **ខ. ម៉ាស៊ីនត្រជាក់ដែលមានកង្ហារប្រើម៉ូទ័រ និងម៉ាស៊ីនសម្រាប់ផ្លាស់ប្តូរសីតុណ្ហភាព និងសំណើម រួមបញ្ចូលម៉ាស៊ីនសំណើមទាំងនោះដែលមិនអាចបែកស្មើគ្នាបាន[២]** | |

| | |
|---|---|
| **- ប្រភេទនៅតាមបង្អួច និងជញ្ជាំងដែលមានតួតែមួយ ឬ "ប្រព័ន្ធបំបែក":** | |
| - - មានថាមពលមិនលើស ២១.១០ KW | 8415.10.10 |
| - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.10.20 |
| - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.10.30 |
| - - មានថាមពលលើសពី ៥២.៧៥ KW | 8415.10.40 |
| **- ប្រភេទប្រើសម្រាប់មនុស្សនៅក្នុងយានយន្ត** | 8415.20.00 |
| **- ម៉ាស៊ីនត្រជាក់ផ្សេងទៀត:** | |
| - - ម៉ាស៊ីនត្រជាក់ដែលមានផ្នែកបញ្ចេញធាតុត្រជាក់ និងមានសន្ទះបិទសម្រាប់ធ្វើឱ្យត្រជាក់វិញ ឬប្តូរកំដៅ (ប្រដាប់ដែលអាចធ្វើឱ្យមានកំដៅឡើងវិញ): | |
| - - - សម្រាប់ប្រើនៅក្នុងយន្តហោះ: | |
| - - - - មានថាមពលមិនលើស ២១.១០ KW | 8415.81.11 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.81.12 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.81.13 |
| - - - - មានថាមពលលើសពី ៥២.៧៥ KW | 8415.81.14 |
| - - - សម្រាប់ប្រើនៅក្នុងអយស្ម័យាន: | |
| - - - - មានថាមពលមិនលើស ២១.១០ KW | 8415.81.21 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.81.22 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.81.23 |
| - - - - មានថាមពលលើសពី ៥២.៧៥ KW | 8415.81.24 |
| - - - សម្រាប់ប្រើនៅក្នុងយានយន្ត: | |
| - - - - មានថាមពលមិនលើស ២១.១០ KW | 8415.81.31 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.81.32 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.81.33 |
| - - - - មានថាមពលមិនលើសពី ៥២.៧៥ KW | 8415.81.34 |
| - - - សម្រាប់ប្រើនៅកន្លែងផ្សេងទៀត: | |
| - - - - មានថាមពលមិនលើស ២១.១០ KW | 8415.81.91 |

| | |
|---|---|
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW. | 8415.81.92 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.81.93 |
| - - - - មានថាមពលលើសពី ៥២.៧៥ KW | 8415.81.94 |
| **- ម៉ាស៊ីនត្រជាក់ផ្សេងទៀត:** | |
| - - ម៉ាស៊ីនត្រជាក់ផ្សេងទៀតដែលមានផ្នែកបញ្ចេញធាតុត្រជាក់ : | |
| - - - សម្រាប់ប្រើនៅក្នុងយន្តហោះ : | |
| - - - - មានថាមពលមិនលើសពី ២១.១០ KW | 8415.82.11 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.82.12 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.82.13 |
| - - - - មានថាមពលមិនលើសពី ៥២.៧៥ KW | 8415.82.14 |
| - - - សម្រាប់ប្រើនៅក្នុងអយស្ម័យាន : | |
| - - - - មានថាមពលមិនលើសពី ២១.១០ KW | 8415.82.21 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.82.22 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.82.23 |
| - - - - មានថាមពលលើសពី ៥២.៧៥ KW | 8415.82.24 |
| - - - សម្រាប់ប្រើនៅក្នុងយានយន្ត : | |
| - - - - មានថាមពលមិនលើសពី ២១.១០ KW | 8415.82.31 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.82.32 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.82.33 |
| - - - - មានថាមពលលើសពី ៥២.៧៥ KW | 8415.82.34 |
| - - - សម្រាប់ប្រើនៅកន្លែងផ្សេងទៀត : | |
| - - - - មានថាមពលមិនលើស ២១.១០ KW | 8415.82.91 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.82.92 |
| - - - - មានថាមពលលើស ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.82.93 |
| - - - - មានថាមពលលើសពី ៥២.៧៥ KW | 8415.82.94 |

| | |
|---|---|
| - - ម៉ាស៊ីនត្រជាក់ផ្សេងទៀតដែលមិនមានផ្នែកបញ្ចេញធាតុត្រជាក់: | |
| - - - សម្រាប់ប្រើនៅក្នុងយន្តហោះ : | |
| - - - - មានថាមពលមិនលើស ២១.១០ KW | 8415.83.11 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.83.12 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.83.13 |
| - - - - មានថាមពលលើសពី ៥២.៧៥ KW | 8415.83.14 |
| - - - សម្រាប់ប្រើនៅក្នុងអយស្ម័យាន : | |
| - - - - មានថាមពលមិនលើសពី ២១.១០ KW | 8415.83.21 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.83.22 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.83.23 |
| - - - - មានថាមពលលើសពី ៥២.៧៥ KW | 8415.83.24 |
| - - - សម្រាប់ប្រើនៅក្នុងយានយន្ត : | |
| - - - - មានថាមពលមិនលើសពី ២១.១០ KW | 8415.83.31 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.83.32 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.83.33 |
| - - - - មានថាមពលលើសពី ៥២.៧៥ KW | 8415.83.34 |
| - - - សម្រាប់ប្រើនៅកន្លែងផ្សេងទៀត : | |
| - - - - មានថាមពលមិនលើសពី ២១.១០ KW | 8415.83.91 |
| - - - - មានថាមពលលើសពី ២១.១០ KW តែមិនលើសពី ២៦.៣៨ KW | 8415.83.92 |
| - - - - មានថាមពលលើសពី ២៦.៣៨ KW តែមិនលើសពី ៥២.៧៥ KW | 8415.83.93 |
| - - - - មានថាមពលលើសពី ៥២.៧៥ KW | 8415.83.94 |
| **គ. ទូទឹកកក ទូបង្កក សម្រាប់ប្រើតាមគេហដ្ឋាន និងសម្រាប់ពាណិជ្ជកម្ម(២)** | |
| **- ទូទឹកកកចំរុះ និងបង្កកចូលគ្នា មានទ្វារខាងក្រៅដាច់ដោយឡែក :** | |
| - - ប្រភេទដាក់ក្នុងផ្ទះ | 8418.10.10 |

| | |
|---|---|
| - - ផ្សេងទៀត | 8418.10.90 |
| **- ទូទឹកកក ប្រភេទប្រើនៅក្នុងផ្ទះ :** | |
| - - ប្រភេទប្រើសម្ពាធ | 8418.21.00 |
| - - ប្រភេទស្រូបដើរដោយចរន្តអគ្គិសនី | 8418.22.00 |
| - សម្រាប់ប្រើនៅកន្លែងផ្សេងទៀត : | 8418.29.00 |
| **- ប្រភេទទូបង្កក មានចំណុះមិនលើស ៨០០ លីត្រ :** | |
| - - មានចំណុះមិនលើស ២០០ លីត្រ | 8418.30.10 |
| - - មានចំណុះលើស ២០០ លីត្រ តែមិនលើសពី ៨០០ លីត្រ | 8418.30.20 |
| **- ប្រភេទទូបង្កកឈរត្រង់មានចំណុះមិនលើស ៩០០លីត្រ :** | |
| - - មានចំណុះមិនលើស ២០០ លីត្រ | 8418.40.10 |
| - - មានចំណុះលើស ២០០ លីត្រ តែមិនលើសពី ៩០០ លីត្រ | 8418.40.20 |
| **- ប្រភេទទូបង្កក និងទូទឹកកកផ្សេងទៀត ដែលមានកុងទ័របង្ហាញ និងទូសម្ភារីម ទឹកកក និងបង្កកប្រហាក់ប្រហែល ។** | |
| - - ចំណុះមិនលើសពី ២០០ លីត្រ : | |
| - - - សម្រាប់ការប្រើប្រាស់ខាងពេទ្យ | 8418.50.11 |
| - - - ផ្សេងទៀត | 8418.50.19 |
| - - ចំណុះលើសពី ២០០ លីត្រ : | |
| - - - សម្រាប់ការប្រើប្រាស់ខាងពេទ្យ | 8418.50.21 |
| - - - បន្ទប់ត្រជាក់ | 8418.50.22 |
| - - - ផ្សេងទៀត | 8418.50.29 |
| **- ឧបករណ៍ ទូទឹកកក និងទូបង្កក ដទៃទៀត ស្នប់កំដៅ :** | |
| - - ប្រភេទប្រើសម្ពាធ មានកុងដង់សាទ័រ ផ្លាស់ប្តូរកំដៅ | |
| - - - ប្រដាប់ធ្វើឱ្យទឹកត្រជាក់ដោយមានកម្លាំងធ្វើឱ្យត្រជាក់លើសពី២១.១០ KW ។ ឧបករណ៍ធ្វើឱ្យត្រជាក់មានចំណុះ ១០ តោន ឬច្រើនជាង និងភាពត្រជាក់ ២០ អង្សា ឬច្រើនជាង ។ កុងដង់សាទ័រអេវ៉ាប៉ូរ៉ាទ័រ មានរ៉ាឌីយាទ័រកំដៅ ៣០ ០០០ គក្រ កាឡូរី/ម៉ោង ឬច្រើនជាងសម្រាប់ឧបករណ៍ធ្វើឱ្យត្រជាក់ ។ អេវ៉ាប៉ូរ៉ាទ័រនៃ ប្រភេទហ្វីន មានចន្លោះចំងាយ ៤ មម ឬច្រើនជាង ។ អេវ៉ាប៉ូរ៉ាទ័រនៃប្រភេទធ្វើ ឱ្យកករាងជាបន្ទះ ឬប្រភេទធ្វើឱ្យកកកុងតាក់ ។ | 8418.61.10 |

| | | |
|---|---|---|
| | - - - ផ្សេងទៀត | 8418.61.90 |
| | - - ផ្សេងទៀត : | |
| | - - - ធុងឬប្រអប់ដាក់គេសជ្ជៈឱ្យត្រជាក់ | 8418.69.10 |
| | - - - ប្រដាប់ធ្វើឱ្យទឹកត្រជាក់មានចំណុះធ្វើឱ្យត្រជាក់ ១០០ តោន ឬច្រើន ជាង និងមានកម្លាំងលើសពី ២១.១០ KW | 8418.69.20 |
| | - - - ធុងឬប្រអប់ប្រដាប់ដាក់ទឹកឱ្យត្រជាក់ | 8418.69.30 |
| | - - - ស្នប់កំដៅនៃប្រភេទមិនសម្រាប់ប្រើក្នុងផ្ទះ | 8418.69.40 |
| | - - - ឧបករណ៍ផលិតទឹកកក | 8418.69.50 |
| | - - - ផ្សេងទៀត | 8418.69.90 |
| ២ | **ផលិតផលកំប៉ុងបាញ់ស្រ្ពៃដែលមានប្រើប្រាស់សារធាតុ** CFCs **និង** HALONS **លើកលែងផលិតផលឱសថ**(៣)<br>(Aerosol products using CFCs and Halons, except medical aerosols) | |
| ៣ | **ឧបករណ៍ពន្លត់អគ្គីភ័យដែលអាចកាន់យួរបាន**(៤)<br>(Portable fire extinguisher)<br>- ឧបករណ៍ពន្លត់ភ្លើង ដែលមានការសាកបញ្ចូល : | |
| | - - ផ្សេងទៀត | 8424.10.90 |
| ៤ | **សារធាតុសម្រាប់បង្កើតសំភារៈប៉ូលីម៉ែរ**(៥) (Pre-polymers)<br>ប៉ូលីមែរអេទីឡែន ក្នុងទម្រង់ដើម<br>**- ប៉ូលីអេទីឡែនមានដង់ស៊ីតេតូចជាង ០,៩៤ :** | |
| | - - ទម្រង់ជាម្សៅ | 3901.10.10 |
| | - - គ្រាប់តូចៗ : | |
| | - - - សារធាតុសម្រាប់ផលិតឱសថ | 3901.10.21 |
| | - - - សាធាតុសម្រាប់ផលិតខ្សែកាប | 3901.10.22 |
| | - - - ផ្សេងទៀត ប្រើសម្រាប់ផលិតខ្សែទូរសព្ទ ឬខ្សែភ្លើង | 3901.10.23 |
| | - - - ផ្សេងទៀត | 3901.10.29 |
| | - - រាវ ឬខាប់ | 3901.10.30 |
| | **- ប៉ូលីអេទីឡែនមានដង់ស៊ីតេ ០,៩៤ ឬច្រើនជាង :** | |

| | |
|---|---|
| - - ទម្រង់ជាម្សៅ | 3901.20.10 |
| - - គ្រាប់តូចៗ : | |
| - - - សម្រាប់ផលិតខ្សែកាប | 3901.20.21 |
| - - - ផ្សេងទៀត. ប្រើសម្រាប់ផលិតខ្សែទូរសព្ទ័ ឬខ្សែភ្លើង | 3901.20.22 |
| - - - ផ្សេងទៀត | 3901.20.29 |
| - - រាវ ឬខាប់ | 3901.20.30 |
| - - ទម្រង់ផ្សេងទៀត | 3901.20.90 |
| **- កូប៉ូលីមែរ អាសេតាតវីនីល អេទីឡែន :** | |
| - - ទម្រង់ជាម្សៅ | 3901.30.10 |
| - - គ្រាប់តូចៗ | 3901.30.20 |
| - - រាវ ឬខាប់ | 3901.30.30 |
| - - ផ្សេងទៀត | 3901.30.90 |
| **- ផ្សេងទៀត :** | |
| - - ទម្រង់ជាម្សៅ | 3901.90.10 |
| - - គ្រាប់តូចៗ | 3901.90.20 |
| - - រាវ ឬខាប់ | 3901.90.30 |
| - - ផ្សេងទៀត | 3901.90.90 |

**កំណត់សម្គាល់**

(១) - ចំពោះផលិតផលដែលមិនប្រើប្រាស់ ឬពុំមានផ្ទុកសារធាតុបំផ្លាញស្រទាប់ អូហ្សូន មិនចាំបាច់ត្រូវចុះបញ្ជីនៅក្រសួង បរិស្ថានឡើយ ។

(២) -ម៉ាស៊ីនត្រជាក់ និងឧបករណ៍ធ្វើឱ្យត្រជាក់ដែលមានផ្ទុក ឬសម្រាប់ប្រើប្រាស់សារធាតុដែលមានចែងនៅឧបសម្ព័ន្ធទី១ ផ្នែក ក ក្រុមទី១ ក្លរ៉ូភ្លុយអ័រ៉ូកាបូន (Chlorofluorocabons-CFCs) ដែលជាសារធាតុត្រជាក់ ។

(៣) -ផលិតផលកំប៉ុងបាញ់ស្រ្តេអាអេរ៉ូសុល ដែលមានផ្ទុកសារធាតុនៅក្នុង ឧបសម្ព័ន្ធទី១ ផ្នែក ក ក្រុមទី១ ក្លរ៉ូភ្លុយអ័រ៉ូកាបូន (Chlorofluorocabons-CFCs) ជាសារធាតុត្រជាក់ ម្សៅផ្តល់កម្លាំងរុញ (propellants) ។ បណ្តា ផលិតផលកំប៉ុង ឬកំប៉ុងបាញ់ស្រ្តេទាំងនោះមានជាអាទិ៍: ម្ហូបអាហារ គ្រឿងសំអាង គ្រឿងបន្ទប់ទឹក ថ្នាំសម្លាប់សត្វល្អិត ថ្នាំលាប ប្រេងរំអិល ទឹកសម្រាប់លាង ស៊ីលីកូន (ឧស្ម័នបង្ហូរ ទឹកភ្នែក) ។ល ។

(៤) -ឧបករណ៍ពន្លត់អគ្គិភ័យដែលអាចកាន់យួរបាន មានផ្ទុកសារធាតុចែងនៅក្នុងឧបសម្ព័ន្ធទី១ ផ្នែក ក ក្រុមទី២ ហាឡូន (Halon) រួមមាន ឧបករណ៍ពន្លត់អគ្គិភ័យដែលអាចយួរដៃ និងប្រព័ន្ធការពារអគ្គិភ័យអចិន្ត្រៃយ៍ ។

(៥) -ផលិតផលទាំងឡាយដែលដំណើការផលិតកម្មមានប្រើប្រាស់សារធាតុ ដូចមានចែងនៅឧបសម្ព័ន្ធទី១ ផ្នែក ក ក្រុមទី១ ដែលជាក្លរ៉ូភ្លុយអ័រ៉ូកាបូន (Chloro-fluorocabons-CFCs) និងផ្នែក ខ ក ក្រុមទី២ និងក្រុមទី៣ ដែលជាកាបូនតេត្រាក្លរ៉ាយ(Carbontetrachloride) និង ១-១-១-ទ្រីក្លរ៉ូអេតាន (1,1,1-trichloroethane or Methyl chloroform ) ជាសារធាតុភាវរំលាយ ឬជាពពុះ (Foam) ។

(៦) - លេខសម្គាល់ក្នុងតារាងពន្ធគយកម្ពុជានៅក្នុងអនុក្រឹត្យនេះនឹងអាចផ្លាស់ប្តូរបានតាមការចាំបាច់នៃតារាងពន្ធគយកម្ពុជា ដោយរក្សាខ្លឹមសារនៃប្រភេទទំនិញនៅដដែល ។